**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ៖ ៧៤៥/២២ [illegible]

# ជម្រាបជូន

## ឯកឧត្តម អភិបាល នៃគណៈអភិបាល និងជាប្រធានគណៈកម្មាធិការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានីភ្នំពេញ

**កម្មវត្ថុ៖** សំណើសុំជួយសម្របសម្រួលផលិត និងចងបដាពាក្យស្លោក នៅតាមមហាវិថីមួយចំនួន សម្រាប់ផ្សព្វផ្សាយក្នុងទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ។

**យោង៖** ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម អភិបាល** ជ្រាបថា៖ ក្នុងឆ្នាំ២០២២ នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ដែលមានអ្នកចូលរួមប្រមាណ ៣.០០០ អង្គ/នាក់។

***កម្មវិធីនឹងប្រព្រឹត្តទៅនាថ្ងៃ ចន្ទ ៤រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។***

(**ជូនភ្ជាប់ជាមួយ៖** នូវកម្មវិធីចំនួន ០១ច្បាប់ និងខ្លឹមសារនៃបដា សម្រាប់ផ្សព្វផ្សាយ ០១ច្បាប់)

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម អភិបាល** មេត្តាជួយសម្របសម្រួលផលិត និងចងបដាពាក្យស្លោកនៅតាមមហាវិថីមួយចំនួន ដើម្បីផ្សព្វផ្សាយឱ្យបានជ្រួតជ្រាបដល់គ្រប់ស្រទាប់មហាជនអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងគ្រប់ទម្រង់។

សូម **ឯកឧត្តម អភិបាល** មេត្តាទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ៕

*ថ្ងៃអង្គារ ១៤រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០២២*

**អនុប្រធានអចិន្ត្រៃយ៍**

**ជូ ប៊ុនអេង**

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សាររួម

## សម្រាប់កម្មវិធី ទិវាជាតិ ១២ ធ្នូ ឆ្នាំ ២០២២

1- រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព
Unite to Eliminate Human Trafficking Towards Achieving the National Sustainable Development Goals .

2- យើងទាំងអស់គ្នា ប្រឆាំងដាច់ខាត ចំពោះបទឧក្រិដ្ឋនៃអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មដទៃទៀត
We're All Fighting for The Crime of Human Trafficking and Other Crimes .

3- សូមគាំទ្រ គោលនយោបាយរាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ ជីវភាពកម្មករ កសិករ មន្ត្រីរាជការ ដើម្បីកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន
We Support Strongly the Government Policy to Improve the Living Conditions of Workers, Farmers and Civil Servants to Reduce Risk of Migration .

4- យើងទាំងអស់គ្នា គ្រប់ភេទ គ្រប់វ័យ មិនមែនជាទំនិញ សម្រាប់ឱ្យជនល្មើសជួញដូរ ឬកេងប្រវ័ញ្ចឡើយ
All Of Us, Of All Ages, Are Not Goods for Human Traffickers or Exploitation .

5- យើងគាំទ្រ និងជំរុញការផ្តន្ទាទោសជនល្មើស ដើម្បីផ្តល់យុត្តិធម៌ជូនជនរងគ្រោះ
We Support and Promote Prosecution of Perpetrators to Provide Justice to Victims .

6- ប្រឆាំងដាច់ខាត ការប្រើប្រាស់ទឹកដីកម្ពុជា ជាកន្លែងប្រព្រឹត្តបទឧក្រិដ្ឋជួញដូរមនុស្ស!
Absolutely Fight Against the Use of Cambodian Territory as the Place or Destination for Trafficking crime!

7- យើងត្រូវបង្កើនការយល់ដឹង អំពីល្បិចកលជនល្មើស ផលប៉ះពាល់នៃអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចគ្រប់រូបភាព ដើម្បីសុវត្ថិភាពសហគមន៍យើង
We Must Expand Awareness of the offender's tricks, impacts of Human Trafficking and all forms of exploitation for our community to be safe .

8- យើងរួមគ្នាធ្វើអំពើល្អ ជួយថែទាំ និងមិនរើសអើងជនរងគ្រោះដែលមានក្នុងសហគមន៍យើង ជាពិសេស ស្ត្រី និងកុមារ

Together We Do Good Deeds to Help, Care for And Not Discriminate Against Victims in Our Community, Especially Women and Children .

9- យើងទាំងអស់គ្នា គ្រប់ភេទ គ្រប់វ័យ មិនមែនជាទំនិញ សម្រាប់ឲ្យជនល្មើសជួញដូរ ឬកេងប្រវ័ញ្ចឡើយ

All of us, of all ages, are not goods for human traffickers or exploiters

10- ប្តេជ្ញាពង្រីកការយល់ដឹង អំពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ទៅសហគមន៍យើង ដើម្បីបានរួចផុតពីភាពរងគ្រោះ

Commit to expand awareness of the impact of human trafficking to our community in order to escape the suffering.

11- យើងរួមគ្នាធ្វើអំពើល្អ ជួយថែទាំ និងមិនរើសអើងជនរងគ្រោះដែលមានក្នុងសហគមន៍យើង ជាពិសេស ស្ត្រី និងកុមារ

Together we do good deeds to help, care for and not discriminate against victims in our community, especially women and children.